**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ០០៣ សរណន

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១

## សារាចរណែនាំ

### ស្តីពី

### ការរៀបចំគ្រប់គ្រងចរន្តភ្ញៀវទេសចរនៅតាមមូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍ រមណីយដ្ឋាន និងគោលដៅទេសចរណ៍ទូទាំងប្រទេស នាឱកាសឈប់សម្រាកពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃពុធ ៣កើត ដល់ថ្ងៃសុក្រ ៥កើត ខែពិសាខ ត្រីស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ដល់ ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១

**យោង** : - ព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

- អនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- សារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ ស្តីពីការឈប់សម្រាកក្នុងពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ របស់រាជរដ្ឋាភិបាល
- ប្រកាសលេខ ០៨១ ស.នក.ប្រក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ ស្តីពីកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពក្នុងអំឡុងពេលនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ របស់ក្រសួងសុខាភិបាល។

ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលអាចកើតមានជាយថាហេតុនាឱកាសពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ក្រសួងទេសចរណ៍សូមធ្វើការណែនាំដូចខាងក្រោម៖

**១.** គ្រប់មូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍ រមណីយដ្ឋាន និងគោលដៅទេសចរណ៍ទូទាំងប្រទេស និងភ្ញៀវទេសចរទាំងអស់ ត្រូវអនុវត្តឱ្យបានយ៉ាងខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់នូវវិធានការទាំងឡាយដែលបានដាក់ចេញដោយក្រសួងសុខាភិបាល និងវិធានសុវត្ថិភាពទេសចរណ៍របស់ក្រសួងទេសចរណ៍ ក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ពិសេស**វិធានការ "៣ ការពារ"** គឺពាក់ម៉ាស់ លាងដៃ **និងរក្សាគម្លាតសុវត្ថិភាព និងវិធានការ "៣ កុំ" គឺកុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ កុំចូលទៅកន្លែងដែលបិទជិតឃឹង និងកុំប៉ះពាល់គ្នា។**

**២.** គ្រប់មូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍ រមណីយដ្ឋាន និងគោលដៅទេសចរណ៍ទាំងអស់ ត្រូវធ្វើការកត់ត្រាភ្ញៀវទេសចរទាំងអស់ ដែលចូលកម្សាន្ត និងប្រើប្រាស់សេវានៅក្នុងកន្លែងរបស់ខ្លួន ជា

ផ្ទះលេខ៣A ផ្លូវលេខ១១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

ពិសេសអាសយដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង។ ទន្ទឹមនឹងនេះ គ្រប់មូលដ្ឋានទាំងអស់ ត្រូវចុះឈ្មោះ បង្កើត និងប្រើប្រាស់**ប្រព័ន្ធ QR Code ទប់ស្កាត់កូវីដ-១៩** និងតម្រូវឱ្យភ្ញៀវទេសចរត្រូវតែស្កេនជាដាច់ខាត មុនចូលទៅក្នុងកន្លែងរបស់ខ្លួន។

៣. ត្រូវរៀបចំនូវការត្រួតពិនិត្យកំដៅ ការបាញ់អាល់កុលសម្លាប់មេរោគគ្រប់ភ្ញៀវទេសចរ និងត្រូវរៀបចំឱ្យមានអាល់កុលបាញ់សម្លាប់មេរោគ និងសម្រាប់លាងដៃឱ្យបានគ្រប់គ្រាន់ និងគ្រប់ទីកន្លែងដែលចាំបាច់ ហើយភ្ញៀវទេសចរត្រូវតម្រូវឱ្យពាក់ម៉ាស់ស្របតាមគោលការណ៍សុខាភិបាល។

៤. គ្រប់មូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍ រមណីយដ្ឋាន និងគោលដៅទេសចរណ៍ទាំងអស់ ត្រូវពង្រឹងការគ្រប់គ្រងឱ្យបានល្អប្រសើរ ពិសេសត្រូវកំណត់**សមត្ថភាពផ្ទុក** (Carrying Capacity) អតិបរមាដែលអាចទទួលភ្ញៀវបានក្នុងពេលតែមួយអនុលោមតាមស្តង់ដាគម្លាតសុវត្ថិភាព និងមិនត្រូវទទួលភ្ញៀវលើសពីចំណុះនេះជាដាច់ខាត។ ទន្ទឹមនឹងនេះ ត្រូវជំរុញលើកទឹកចិត្តភ្ញៀវទេសចរឱ្យទៅលំហែកម្សាន្តតែជាមួយធម្មជាតិ និងសក្តានុពលដែលមានក្នុងរមណីយដ្ឋាន និងគោលដៅទេសចរណ៍ ដោយមិនត្រូវរៀបចំឱ្យមានការជួបជុំចំនួនមនុស្សច្រើន និងអឹូរអរជាដាច់ខាត។ ចំពោះការជួបជុំជាក្រុមតូចដែលចាំបាច់ (លក្ខណៈជាក្រុមគ្រួសារផ្ទាល់) នៅក្នុងភោជនីយដ្ឋាន អាហារដ្ឋាន ឬកន្លែងទទួលទានអាហារជុំគ្នាដែលមាននៅក្នុងរមណីយដ្ឋាន និងគោលដៅទេសចរណ៍ ក៏ចាំបាច់ត្រូវតែរក្សាគម្លាតសុវត្ថិភាពបុគ្គលឱ្យបានត្រឹមត្រូវ (យ៉ាងតិច ១,៥ ម៉ែត្រពីគ្នា)។

៥. គ្រប់មូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍ រមណីយដ្ឋាន និងគោលដៅទេសចរណ៍ទាំងអស់ ត្រូវអនុវត្តកាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាព ពិសេសនៅទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល។ ទន្ទឹមនឹងនេះ ត្រូវបិទផ្សាយ និងផ្សព្វផ្សាយនូវសេចក្តីសង្ខេបអំពីច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល និងក្រសួងទេសចរណ៍ ហើយគ្រប់បុគ្គលិក ដែលបម្រើការក្នុងមូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍ រមណីយដ្ឋាន និងគោលដៅទេសចរណ៍នានា ត្រូវពន្យល់ណែនាំអំពីវិធានការទប់ស្កាត់ជំងឺកូវីដ-១៩នេះ ទៅដល់ភ្ញៀវទេសចរ និងតម្រូវឱ្យភ្ញៀវទេសចរចូលរួមអនុវត្តជាកាតព្វកិច្ច។ ក្នុងករណីដែលភ្ញៀវទេសចរពុំអនុវត្តតាម ត្រូវរាយការណ៍ទៅគណៈគ្រប់គ្រង ដើម្បីមានវិធានការបន្ត។

៦. គ្រប់រមណីយដ្ឋាន និងគោលដៅទេសចរណ៍ទាំងអស់ ត្រូវតែមានអ្នកគ្រប់គ្រងច្បាស់លាស់។ ចំពោះគោលដៅទេសចរណ៍ដែលមានលក្ខណៈសាធារណៈ និងដែលពុំទាន់មានអ្នកគ្រប់គ្រងច្បាស់លាស់ ដូចជាគោលដៅទេសចរណ៍ឆ្នេរសមុទ្រ ឆ្នេរទន្លេ គោលដៅអេកូទេសចរណ៍ ទេសចរណ៍ធម្មជាតិ ។ល។ មន្ទីរទេសចរណ៍ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន រៀបចំឱ្យមានគណៈគ្រប់គ្រងមួយច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង អប់រំ និងណែនាំដល់ភ្ញៀវទេសចរ អនុវត្តវិធានការនានាក្នុងការទប់ស្កាត់ការរីករាលជំងឺកូវីដ-១៩។

៧. ព្រមជាមួយវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ គ្រប់មូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍ រមណីយដ្ឋាន និងគោលដៅទេសចរណ៍ទាំងអស់ ត្រូវពង្រឹងគុណភាពផលិតផលទេសចរណ៍ ថែរក្សាបរិស្ថាន-អនាម័យ ជៀសវាងការបោះចោលសំរាមផ្តេសផ្តាស និងរក្សាតម្លៃផលិតផល និងសេវាកម្ម

ឲ្យបានសមរម្យ ដោយរាល់ថ្លៃស្នាក់នៅ ម្ហូបអាហារ និងសេវាផ្សេងៗ ត្រូវសរសេរឲ្យបានច្បាស់ដាក់ក្នុងតារាងដើម្បីជម្រាបជូនភ្ញៀវឲ្យបានដឹងជាមុន ជៀសវាងការកំណត់ថ្លៃខ្ពស់ហួសហេតុ។

៥. គ្រប់មូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍ រមណីយដ្ឋាន និងគោលដៅទេសចរណ៍ទាំងអស់ ត្រូវអនុវត្តសារាចរនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់។ **ករណីខកខានមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមខ្លឹមសារសារាចរណែនាំនេះ មូលដ្ឋានអាជីវកម្ម និងសេវាកម្មទេសចរណ៍ រមណីយដ្ឋាន និងគោលដៅទេសចរណ៍ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ពិសេសច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។**

ទទួលបានសារាចរណែនាំនេះ គ្រប់មន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវសហការជាមួយរដ្ឋបាលរាជធានី ខេត្ត មន្ទីរពាក់ព័ន្ធ និងផ្នែកឯកជន អនុវត្តតាមខ្លឹមសារខាងលើ ឲ្យបានលទ្ធផលល្អប្រសើរក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងត្រូវផ្ញើរបាយការណ៍ប្រចាំថ្ងៃបូកសរុបស្ថិតិ និងស្ថានភាពភ្ញៀវទេសចរនៅតាមគោលដៅទេសចរណ៍នានាផ្ញើមកក្រសួងទេសចរណ៍។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសុខាភិបាល
"ដើម្បីជូនជ្រាប"
-សាលារាជធានី ខេត្ត "ដើម្បីចូលរួមអនុវត្ត"
-មន្ទីរទេសចរណ៍រាជធានី ខេត្ត "ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ